ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ ១០៦៧ អបស.អធម

ថ្ងៃសុក្រ ៣ កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ តុលា ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**
**ជម្រាបជូន**
**- ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**
**- ឯកឧត្តម លោក លោកស្រីប្រធាន អង្គភាពថ្នាក់កណ្តាល**

**កម្មវត្ថុ៖** ការផ្សព្វផ្សាយអំពីការផ្តល់អាហារូបករណ៍ថ្នាក់ Diploma in Medical Microbiology (DMM) and Diploma in Applied Parasitology and Entomology (DAP & E) ចាប់ពីថ្ងៃទី៦ ខែមេសា ដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៦ សិក្សានៅប្រទេសម៉ាឡេស៊ី។

**យោង ៖** លិខិតចុះថ្ងៃទី៩ ខែតុលា ឆ្នាំ ២០២៥ របស់ Southeast Asian Ministers of Education Organization (SEAMEO), Regional Tropical Medicine and Public Health Network (TROPMED)

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជ្រាបថា SEAMEO TROPMED បានផ្សព្វផ្សាយពីការផ្តល់អាហារូបករណ៍ថ្នាក់ Diploma in Medical Microbiology (DMM) and Diploma in Applied Parasitology and Entomology (DAP & E) ចាប់ពីថ្ងៃទី៦ ខែមេសា ដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៦ សិក្សានៅប្រទេសម៉ាឡេស៊ី។

ចំពោះមន្ត្រីដែលមានបំណងចូលរួមវគ្គសិក្សាខាងលើ ត្រូវបំពេញសំណុំបែបបទចំនួន០២ច្បាប់ និងដាក់ពាក្យស្នើសុំនៅនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងសុខាភិបាលដោយផ្ទាល់ តាមរយៈប្រធានអង្គភាព ឱ្យបានមុនថ្ងៃទី៥ ខែមករា ឆ្នាំ ២០២៦។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ធ្វើការផ្សព្វផ្សាយដល់មន្ត្រីក្រោមឱវាទដែលបានតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ និងស្របតាមលក្ខខណ្ឌជ្រើសរើសដាក់ពាក្យចូលរួមឱ្យបានទាន់ថ្ងៃកំណត់។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ទទួលនូវការរាប់អានពីខ្ញុំ។

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

**វេជ្ជ. ម៉ី សំបូរ**

**ចម្លងជូន៖**
-ក្រសួងមហាផ្ទៃ
-ខុទ្ទកាល័យឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល
-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-ឯកសារ កាលប្បវត្តិ

អាសយដ្ឋាន៖ ដីឡូត៍លេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩)
សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖(+៨៥៥) ២៣ ៨៨៥ ៩៧០
អ៊ីមែល៖ info@moh.gov.kh
គេហទំព័រ៖ www.moh.gov.kh
តេឡេក្រាម៖ t.me/MOHCambodia